**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១៧
ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០០
**<u>សាលដីកា</u>**
លេខៈ១៤៧
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............ ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រម
៦-លោក ............ ជាចៅក្រម
៧-លោក ............. ជាចៅក្រម
៨-លោក ............... ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-កញ្ញា .................

**<u>តំណាងមហាអយ្យការ</u>**

-លោក .................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១៤(ក) ចុះថ្ងៃទី១៣-០១-២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៣ ចុះថ្ងៃទី១៧-១១-១៩៩៩ របស់សាលាឧទ្ធរណ៍រវាង :

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះគគរភេទប្រុស ជាតិខ្មែរ របររកស៊ី ប្រធានកងជីវពល មានទីលំនៅសព្វថ្ងៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលក្រសួងកសិកម្ម ។ ឳពុកឈ្មោះគ្រួច បានយូ(ស)ម្តាយឈ្មោះបាន យិន(ស) ប្រពន្ធឈ្មោះស៊ីវ សុខា ។

មានលោក.................មេធាវី

និងចុងបណ្តឹងសាទុក្ខឈ្មោះលឡ ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់បាយ និងគុយទាវទីលំនៅសព្វថ្ងៃផ្ទះលេខ៥៤$E_1$ ផ្លូវ២៧១ សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

មេធាវីលោក ............

**<u>កម្មវត្ថុបណ្តឹង</u>** ប្តឹងសុំជួលអាហារដ្ឋាន និងដាក់អោយដេញថ្លៃ

បានឃើញបណ្តឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ របស់លោកគតប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១៤(ក) ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី១៩-០១-២០០០ របស់តុលាការកំពូល ។ តាមបណ្តឹងចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៩៧ របស់ដើមចោទឈ្មោះលឡ ថា : ខ្លួនប្តឹងសុំជួលអាហារដ្ឋានសលបន្ត រឺ ដាក់ដេញថ្លៃជាសាធារណៈ ដោយហេតុថា ខ្លួនបានជួលអាហារដ្ឋាននេះ ពីនាយកដ្ឋានផលិតកម្ម និងបស់ព្យាបាលនៃក្រសួង កសិកម្មកាលពីឆ្នាំ១៩៨៨ រហូតមកដល់សព្វថ្ងៃ ហើយខ្លួនបានសាងសង់អាហារដ្ឋានសេលីបនេះ តាមលក្ខន្តិកៈសហជីប ចុះថ្ងៃទី២៦-១០-៨៨ នៅឆ្នាំ១៩៩២ ខ្លួន និងនាយដ្ឋានបញ្ហាបាលបានធ្វើកិច្ចសន្យាចុះថ្ងៃទី០១-ធ្នូ១៩៩២ កែប្រែតំលៃជួលឡើង ដល់200$US ក្នុង០១ខែ ដោយរក្សាទុកនូវមាត្រាទាំងអស់ ដែលមានចែងក្នុងលក្ខន្តិកៈជួលនៅឆ្នាំ១៩៨៨ អោយនៅដដែលបានន័យថា បន្តជួលឱ្យខ្លួន០៥ឆ្នាំតទៅទៀត ។

នៅថ្ងៃទី០៥-០៨-៩៦ ខ្លួនបានដាក់ពាក្យសុំជួលបន្តនូវដីអាហារដ្ឋាននោះ ក្នុងរយៈពេល៤០ឆ្នាំ តាមមាត្រា៦ នៃលក្ខន្តិកៈ រួចហើយ ប៉ុន្តែនៅថ្ងៃទី២៨-០១-៩៧ រដ្ឋមន្ត្រីក្រសួងកសិកម្ម បានចេញលិខិតលេខ៤២៨ កសក. បានសម្រេចជួលទីតាំងអាហារ ដ្ឋាននោះឱ្យទៅឈ្មោះសជទៅវិញដោយពុំបានឱ្យខ្លួនដឹង ហើយកិច្ចសន្យានោះទៀតសោតពុំទាន់ផុតកំណត់ជួលនៅឡើយ ។ ម្យ៉ាងទៀតពាក្យសុំជួលអាហារដ្ឋានរបស់ខ្លួនគឺហានឱ្យថ្លៃ300$US ដូចឈ្មោះសជដែរហេតុអ្វីបានជាមិនជួលបន្តឱ្យខ្លួនបែរជា សំរេចជួលឱ្យគេផ្សេងទៅវិញ ។ ខ្លួនជាអ្នកសាងសង់អាហារដ្ឋាននោះយ៉ាងលំបាក ហើយតស៊ូក្នុងការលក់ដូរតាំងពីពុំខាន់មានភ្ញៀវរហូតមកដល់សព្វថ្ងៃ មានភ្ញៀវដ៏ច្រើនដោយប្រើរយៈពេល០៩ឆ្នាំមកហើយហេតុអ្វីពុំផ្តល់អាទិភាពឱ្យខ្លួនជួលបន្ត ។ ខ្លួនសំណូមពរសុំជួលអាហារដ្ឋាននេះបន្តដូចតម្លៃក្រសួងកសិកម្មសម្រេចជួលឱ្យទៅឈ្មោះសជនិងសុំទាមទារជំងឺចិត្តដោយសារការបញ្ឈប់ អាជីវកម្មរបស់ខ្លួន មុនពេលផុតកិច្ចសន្យាជួល និង ប្រកថ្លៃចំណូលដែលបង់ខាត ។

តាមពាក្យបណ្តឹងតបន្ទុះថ្ងៃទី០៨-១០-៩៧ របស់នាយកដ្ឋានបសុព្យាបាល និងផលិតកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានប្តឹងសុំរំលាយលក្ខន្តិកៈចុះថ្ងៃទី២៦-១០-៨៨ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលជាមួយនិងលោកទសអ្នកស្រីលឡនិងអ្នកស្រី វឌ ទុកជាមោឃៈ ដោយហេតុថា លក្ខន្តិកៈថុនថ្ងៃទី២៦-០៦-៨៨ បានកំណត់រយៈពេលជួលតែ០៥ឆ្នាំទេ តាមមាត្រា៧នៃលក្ខន្តិកៈល្អដល់ពេលកំណត់ សាមីអាហារដ្ឋានសេស៊ីប មិនព្រមគោរពតាមកិច្ចសន្យា ឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៤០(ក)ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ ១៩៩៧ របស់តុលាការក្រុងភ្នំពេញដែលមាន ខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះលឡ ចុះថ្ងៃទី០៣-០៦-៩៧ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់

២-ទទួលពាក្យបណ្ដឹងរបស់ចុង ចម្លើយនាយកដ្ឋានផលិតកម្មសុព្យាបាលក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ទទួលលិខិតផ្ទេរសិទ្ធិរបស់ឈ្មោះលឡចុះថ្ងៃទី០៤-០៦-៩៧ ឱ្យមេធាវីឈ្មោះ............ ជាតំណាងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៤-ទទួលលិខិតប្រគល់សិទ្ធិរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលក្រសួងកសិកម្មឱ្យឈ្មោះហ៊ួត សម្បត្តិ ប៊ូធឿន និងគគរចុះថ្ងៃទី០៨-០៩-៩៧ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥- ទទួលលិខិតសុំពឹងពាក់មេធាវីឈ្មោះ............ របស់នាយកដ្ឋានបសុព្យាបាលចុះថ្ងៃទី ២៩-០៩-៩៧ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៦- រំលាយលក្ខន្តិកៈសហជីព ស្តីពីការបើក និងដំណើរការអាហារដ្ឋានលេខ៥០-៦៦៥-សជមផប ចុះថ្ងៃទី២៦-១០-១៩៨៨ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា១០៧ នៃក្រិត្យច្បាប់លេខ ៣៨ ចុះថ្ងៃទី ២៨ ។

៧- បង្គាប់ឱ្យឈ្មោះលឡ ម្ចាស់អាហារដ្ឋានសេលីប តំណាងដោយមេធាវី............ ប្រគល់ទីតាំងដីឡូតិ៍លេខ៤០ ហាវិថីព្រះមុនីវង្ស សង្កាត់ស្រនចក ខណ្ឌដូនពេញរាជធានីភ្នំពេញ និងរុះរើសំណង់ចេញពីដីឡូក៏ ខាងលើ ឱ្យទៅនាយក- ដ្ឋានផលិតកម្ម និងបសុព្យាបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទតំណាង ដោយឈ្មោះហសប បធ និងគគរចាប់ពីថ្ងៃប្រកាសសាលក្រមនេះចូលជាស្ថាពរ ។

៨- រឹបអូសប្រាក់ប្រដាប់ក្តី៧០០០៛ ដែលឈ្មោះលឡ បានបង់ទុករួចជាស្រេចដើម្បីបង់ពន្ធហ្នឹង និង ពន្ធចុះបញ្ជីក្តី១៨០០រង្វាន់ក្រឡាបព្រីកាន់ហើបប្រាក់២០០រង្វាន់អ្នកប្រគល់ដីកាកោះ៥០០៛ ។

៩- បង្គាប់ឱ្យដើមចោទបង់ច្រកំប្រដាបំក្តី ៧០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ដែលចុងចម្លើយបាន បង់ទុករួចជាស្រេច ។

កាលបើហួសកំណត់ឧទ្ធរណ៍ហើយ បង្គាប់ឱ្យដើមចោទសងប្រាក់៧០០០៛ ទៅចុងចម្លើយវិញ ។

១០-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៧៥ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ របស់លោកលឡប្ដឹងមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ១៤០(ក) ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ របស់ តុលាការក្រុងភ្នំពេញលើ សេចក្ដីសម្រេចទាំមូល ។

បានឃើញសាលដីកាលេខ១៥៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ និងមេធាវីកំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ និងមេធាវីដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលបណ្តឹងឧទ្ធរណ៍របស់អ្នកស្រីលឡទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធន៏ចោលដោយទាស់ និងគតិច្បាប់ ។

២- ទទួលស្គាល់ការផ្ទេរសិទ្ធិចុះថ្ងៃទី២២-០២-១៩៩៩ ពីអ្នកស្រីលឡទៅមេធាវីឈ្មោះ............. ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-បដិសេធន៍បណ្តឹងសុំពន្យាពេលរបស់លោកមេធាវីសេង រ៉ុន ចោលជាអសារបង់ ។

៤-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៤០(ក)ចុះថ្ងៃទី២៩-១០-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល។

៥-រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ដែលអ្នកស្រីលឡបានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥០០០៛ សរុប១៣.០០០៛ ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនាពេលសវនាការចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ និងមេធាវីកំបាំង មុខដើមបណ្តឹងឧទ្ធរណ៍ និងបើកផ្លូវប្តឹងទាស់និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ២២ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ១៩៩៩ របស់អ្នកស្រីលឡប្តឹងមិនសុខចិត្តនិងសាលដីកាលេខ១៥៣ ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៨៤ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខគ្រូច គឺរី មេធាវីចុងចម្លើយសចឌណនិងមេធាវីដើមចោទ............កំបាំងមុខឈ្មោះលឡ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី២១-មេសា-១៩៩៩ របស់ឈ្មោះលឡ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-បដិសេធន៍សាលដីកាកំបាំងមុខលេខ១៥៣ ចុះថ្ងៃទី៣០-០៣-៩៩ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

៣-បដិសេធន៍លទ្ធផលដេញថ្លៃធ្វើឡើងដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលមានបេក្ខជនឈ្មោះ លឡ និងសជកាលពីថ្ងៃទី២៦-៩-៩៦ និង២៩-១០-៩៦ ចោលជាអសារបង់ ។

៤-បដិសេធន៍កិច្ចសន្យាជួលអាហារដ្ឋានរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលធ្វើឡើងរវាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងលោកសជចុះថ្ងៃទី០៣-មេសា- ១៩៩៧ ចោលជាអសារបង់ ។

៥-អនុញ្ញាឱ្យ ដើមចោទលឡបន្តធ្វើអាជីវកម្មលក់ដូរក្នុងរយៈពេល២ឆ្នាំ ២៧ថ្ងៃ ដើម្បីបញ្ចប់កិច្ចសន្យាចាប់គិតពីថ្ងៃបន្តការលក់ដូរជាលើកទី២ ។

៦-បង្គាប់ឱ្យនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលក្រសួងកសិកម្មផ្តល់អាហារដ្ឋានសេលីប មកឱ្យដើមចោទឈ្មោះលឡ ធ្វើអាជីវកម្មបន្តថាប់ពីសាលដីកាមានអានុភាពអនុវត្ត ។

៧-បង្គាប់ឱ្យនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលក្រសួងកសិកម្ម សងការខូចខាត ខកខានមិនបានរកស៊ីចំនួន៣០០០០ដុល្លាអាមេរិក និងជំងឺចិត្តចំនួន៥.០០០ដុល្លាអាមេរិក ។

៨-សាលដីកានេះជំនុំជំរះចំពោះមុខគករមេធាវីក្នុងចម្លើយសោម ច័ន្ទឌីណា និងមេធាវីដើមចោទជួ ច័ន្ទធារី កំបាំងមុខឈ្មោះលឡ ថ្ងៃទី៣១-០៥-៩៩ និងប្រកាសជាសាធារណៈថ្ងៃទី០៣-មិថុនា - ១៩៩៩ កំបាំងមុខគូក្តីតែចាទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងសាទុក្ខលេខ១៧៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់លោកសចឌណជាមេធាវី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ២៨៤ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៨៩ ចុះថ្ងៃទី២៨-១០-៩៩ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តី សម្រេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខលេខ១៧៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់លោក................. មេធាវីចិណាយឱ្យលោក គគរ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៨៤ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៩៩ ចុះថ្ងៃ១៩ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលចុងចម្លើយបានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ។

BO -ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩០០០៛ ហើយតម្រូវឱ្យអ្នកស្រើលឡសងប្រាក់ចំនួន១៩.០០០៛ នេះទៅលោកគគរវិញ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០១(ក) ចុះថ្ងៃទី០៦- ០១-២០០០ របស់សាលាឧទ្ធរណ៍ បានជំនុំជំរះសារឡើញវិញចំពោះមុខតំណាងនាយកដ្ឋានផលិតកម្មបស់ព្យាបាលនៃក្រសួងកសិកម្មកំបាំង មុខឈ្មោះលឡ ដែលមានខ្លឹម សារនៃ សេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះជាសមត្ថកិច្ចដោយសាលដីការបស់តុលាការកំពូលបង្វិលសំណុំរឿងនេះមកអោយសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញតាមមាត្រា១១នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពសាលាជំរះក្តី ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៤០(ក) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញទាំងមូល។

៣- សំណូមពររបស់ចុងចម្លើយសុំទាមទារសោហ៊ុយសង់ខាត និងជំងឺចិត្តត្រូវលើកចោល ។ សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងនាយកដ្ឋានផលិតកម្មបសព្យាបាលនៃ ក្រសួងកសិកម្ម កំបាំងមុខឈ្មោះលឡ សម្រេចបើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ០៥ ចុះថ្ងៃទី១០-០១-២០០០ របស់អ្នកស្រីលឡប្តឹងមិនសុខចិត្តសុខចិត្តនិងសាលដីការលេខ០១ប្តូនថ្ងៃទី៦-០១-២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤(ក) ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ បានជំនុំជំរះសារ ឡើញវិញចំពោះមុខបណ្តឹងទាស់លោកគករកំបាំងមុខដើមបណ្តឹងទាស់អ្នកស្រីលឡតែចាត់ទុកជាចំពោះមុខដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១- សម្រេចទទួលបណ្តឹងទាស់របស់លឡ ចុះថ្ងៃទី១០-០១-២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-សម្រេចបដិសេធន៍សាលដីកាសាលាឧទ្ធរណ៍លេខ០១(ក) ចុះថ្ងៃទី០៦-០១-២០០០ សម្រេចកំបាំងមុខចោលជាអសារបង់ ហើយសម្រេចជាថ្មីថា:

ក- សម្រេចបដិសេធន៍លទ្ធផលដេញថ្លៃធ្វើឡើងដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលមានបេក្ខជនឈ្មោះលឡ និងសជកាលពីថ្ងៃទី២៦-០៩-១៩៩៦ និងថ្ងៃទី២៩-១០១-១៩៩៦ ចោលជាអសារបង់ ។

ខ- បដិសេធន៍កិច្ចសនាជួលអាហារដ្ឋានរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ធ្វើឡើងរវាង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងលោកសជចុះថ្ងៃទី០៣-០៤-១៩៩៧ចោលជាអាសារបង់ ។

គ- អនុញ្ញាតអោយលឡ បន្តធ្វើអាជីវកម្មលក់ដូរក្នុងរយៈពេល ២ឆ្នាំ២៧ថ្ងៃ ដើម្បីបញ្ចប់កិច្ចសន្យាចាប់តិតពីថ្ងៃបន្តការលក់ដូរលើកទី២ ។

ឃ- បង្គាប់អោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលក្រសួងកសិកម្មផ្តល់អាហារដ្ឋាន សេលីប មកអោយដើមចោទលឡ ធ្វើអាជីវកម្មបន្តចាប់ពីសាលដីកាមានអានុភាព អនុវត្ត ។

ង- បង្គាប់អោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ក្រសួងកសិកម្ម សងការខូចខាតខក ខាន មិនបានរកស៊ីចំនួន៣០០០០ដុល្លាអាមេរិត (បីម៉ឺនដុល្លាអាមេរិក) និងជំងឺចិត្ត៥០០០ដុល្លា អាមេរិក ប្រាំពាន់ដុល្លាអាមេរិត ទៅអោយលឡ ។

ច- បដិសេធសំណូមពររបស់ក្នុងចម្លើយលោក គគរ តំណាងនាយកដ្ឋានផលិតកម្មបស់ព្យាបាល ក្រសួងកសិកម្ម និងនេសាទ សុំជំងឺចិត្តនិងសាហ៊ុយបង់ខាត ។

សាលដីការនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងបណ្តឹងទាស់លោក គគរ តំណាងអោយនាយកដ្ឋាន ផលិតកម្ម បសុព្យាបាល នៃក្រសួងកសិកម្ម និងនេសាទ កំបាំងមុខដើមបណ្តឹងទាស់អ្នកស្រី លឡតែចាត់ដូចជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី១៣-០១-២០០០ របស់លោកគគរប្តឹងមិនសុខចិត្ត នឹងសាលដីកលេខ១៤(ក) ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២៤-០១-២០០០ របស់លោកគគរ

បានឃើញសារណាតបចូនថ្ងៃទី២៩-០១-២០០០ របស់អ្នកស្រី លឡ

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយករណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈផ្ទុយ និងគតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោកគគរជាចុងចម្លើយ និងជាដើមបណ្តឹងសាទុក្ខចនឆ្លើយនាពេលសវនាការ សាលាឧទ្ធរណ៍ពុំបានកាត់ក្តីដោយយុត្តិធម៌ ដោយព្រមតាមកិច្ចសន្យា លើកទីមួយទេ ការជួលលើកទី២ គ្មានសន្យាទេគ្រាន់តែយកឈ្នួលថ្មីរយៈពេលមួយឆ្នាំគឺបង់២០០ដុល្លា ដោយនាយកដ្ឋានមិនទាន់មានគោលការណ៍ច្បាស់លាស់ គឺទុកពេលអាយអាហារដ្ឋានចេះតែ លក់បន្ត ដោយពុំបានធ្វើកិច្ចសន្យាអ្វីទេ ។ខ្លួនសុំអោយអ្នកស្រីលឡប្រគល់ដីឡូត៍នេះអោយក្រសួងវិញក្រឡាបញ្ជីអានសារណាតបរបស់អ្នកស្រីលឡ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីសោម ច័ន្ទឌីណា តំណាងអោយឈ្មោះ គគរ ជាដើមបណ្តឹងសាទុក្ខនៅពេល សវនាការថា : នាយកដ្ឋានបសុព្យាបាល បានជួលដីឡូតិ៍លេខ៤០ អោយទៅឈ្មោះឡសវឌ និងលឡបើកអាហារដ្ឋាន ឈ្មោះសលក្នុងរយៈពេល៥ឆ្នាំ លុះផុតកំណត់ តំណាងអាហារដ្ឋានសុំជួលបន្ត តែសហជីពពុំព្រម ដោយហេតុថាដី ឡូត៍នេះ សហជីពបានប្រគល់ជូន នាយកដ្ឋាន និង

ក្រសួងកសិកម្មទៅហើយ តែដោយនាយកដ្ឋានមិនទាន់មានគោលការច្បាស់ លាស់ បានទុកពេលអោយអាហារដ្ឋានលក់បន្តជាបណ្ដោះអាសន្ន ពុំមែនមានលក្ខខ័ណ្ឌថាជួលបន្ត រឺជាប់កិច្ចសន្យាជាមួយតំណាងអាហារដ្ឋានក្នុងរយៈពេល ៥ឆ្នាំ នោះទេ ព្រោះក្នុងលំអិតមួយឆ្នាំចុងក្រោយមិនមានចែង ។ ដល់ឆ្នាំ ១៩៩៦ ក្រសួងមានផែនការថ្មី ដោយអោយធ្វើការដេញថ្លៃតាមនិតិវិធីកំណត់របស់នាយកដ្ឋាន ។

**<u>សំណូមពរ</u>**

-សុំតម្កល់សាលក្រមលេខ១៤០(ក) ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញទុកជាបានការពេញទាំងមូល ។

សុំតម្កល់សាលដីការកំបាំងមុខលេខ១៥៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៩ របសឧទ្ធរណ៍ទុកជាបានការ ដដែលសុំបដិសេធសាលដីកាលេខ២៨៤ ចុះថ្ងៃទី០៣-០៦-៩៩ របស់សាលាឧទ្ធរណ៍

សុំប្រគល់ទីតាំងដីឡូត៏លេខ៤០ វិថីព្រះមុនីវង្សសង្កាត់ស្រះចេក ខណ្ឌដូនពេញ ក្រុងភ្នំពេញ មកនាយកដ្ឋានបសុព្យាបាល និង ផលិតកម្មវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី............ តំណាងអោយអ្នកស្រីលឡជាចុងបណ្តឹងសាទុក្ខនាពេលសវនាការថា មុននិងធ្វើសេចក្តីសន្និដ្ឋានខ្លួនសុំធ្វើការសោកស្តាយពីការដាក់ពាក្យពន្យាពេលសវនាការរបស់អ្នកស្រីលឡដោយគាត់មានជំងឺនៅមន្ទីពេទ្យ ។ ហើយនិងសុំសួរថា តើលោកគគរគាត់មានឋានៈជាអ្វីនៅក្នុងក្រសួងក្នុងការធ្វើការប្តឹងនេះ?

តុលាការកំពូលសម្រេចបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញដោយតុលាការកំពូលមានការភ័ន្តច្រឡំមិនបកស្រាយអោយបានច្បាស់លាស់ នូវអ្វីទៅដែលហៅថាអត្ថិភាព? នៅក្នុងការដេញថ្លៃតុលាការកំពូលថា នេះជានិតិវិធីរបស់ក្រសួង នោះជាការមិនត្រឹមត្រូវទេ ក្នុងការដេញថ្លៃចាំបាច់ត្រូវធ្វើក្នុងថ្ងៃជាមួយគ្នា ហើយត្រូវមើលលើច្បាប់ដេញថ្លៃរបស់ក្រសួងពាណិជ្ជកម្ម ។

ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានដូចក្នុងសារណារបស់កូនក្តីខ្លួន ។

-ក្រោយពីបានស្លាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្លាប់សេចក្តីសន្និដ្ឋានរបស់តំណាងមម្រោអយ្យការ

-ក្រោយពីបានស្លាប់ចំលើយរបស់តំណាងនាយកដ្ឋានផលិតកម្មបញ្ញាបាល សារណារបស់អ្នកស្រីលឡនិងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ២៤ ចុះថ្ងៃទី១៣-១១-២០០០ របស់លោក គគរ ប្តឹងពីសាលដីការដ្ឋប្បវេណីលេខ១៤(ក) ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូលធ្វើ ឡើងក្នុងកំណត់ច្បាប់តុលា ការកំពូល អាចលើករឿងនេះមកជំនុំជំរះរួមក្រុមដល់អង្គសេចក្តីបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាព របស់សាលាជំរះក្តីនិងមាត្រា២២៦ នៃច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីដែរ ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក្នុងការជំនុំជំរះជាថ្មីសម្រេចអោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលនៃក្រសួង កសិកម្មជួលអាហារដ្ឋាន បន្តអោយអ្នកស្រីលឡដោយសំអាងទៅលើសារណារបស់អ្នកស្រីលឡទាំងស្រុង និងពុំបាន ពិចារណាលើអង្គហេតុអោយបានត្រឹមត្រូវនោះ ជាការភ័ន្តច្រឡំ និងជាការបំពានទៅនិងគោលការ នៃការស៊ើបអង្កេត ។

យល់ឃើញថា ក្រោយពេលចប់កិច្ចសន្យាជួលលើកទី១ គូភាគីពុំបានធ្វើកិច្ចសន្យាណាមួយជាលាយលក្ខអក្សរទេដូច្នេះ ការជួលបន្តនេះជាការជួលបន្តដោយពុំមានកំណត់ថេរវេលាដូចដែលកំណត់នៃមាត្រា១០១ និង ១១០ នៃក្រិត្យច្បាប់លេខ៣៨ក្រ-ច ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅតិច្ចសន្យា ។ ហើយការដែលអ្នកស្រីលឡដាក់ពាក្យសុំជួលអាហារដ្ឋានបន្ត នៅឆ្នាំ១៩៩៦ នោះបញ្ជាក់ថា អ្នកស្រីក៏ទទួលស្គាល់ដែរជាការជួលបន្ត របស់អ្នកស្រីពីមុនមកពុំមានកំណត់ថេរវេលាទេ ។

យល់ឃើញថា ការដែលមេធាវី ដើមចោទលើកឡើងថាកូនក្តីលោកមានសិទ្ធិជួលអាហារដ្ឋានបន្តតាមកំណត់ហេតុចុះថ្ងៃទី២៦-១០-៩២ នោះគឺជាការភ័ន្តច្រឡំពីព្រោះថា កំណត់ហេតុនេះគ្រាន់តែបញ្ញាកំលក្ខខណ្ឌសំរាប់អនុវត្តឆ្នាំចុងក្រោយនៃកិច្ចសន្យា ប៉ុណ្ណោះ សូម្បីតែអ្នកស្រីលឡក៏បានដាក់ពាក្យសុំជួលអាហារដ្ឋាននោះបន្តចុះថ្ងៃទី០៥-៨-៩៦ ទៀតដែរ ដែលបញ្ជាក់ថា អ្នកស្រីលឡក៏បានដឹងច្បាស់ថាការជួលអាហារដ្ឋានបន្តក្នុងតម្លៃ ២០០ដុល្លាអាមេរិក ក្នុង១ខែមិនមានរយៈពេល៥ឆ្នាំទេ។ ម្យ៉ាងទៀតអ្នកស្រីក៏បានចូលរួមដេញថ្លៃអាហារដ្ឋាននេះមុនការកំណត់ ៥ឆ្នាំដែរដូចមានកំណត់ហេតុ ចុះថ្ងៃទី២៦-៩-៩៦ស្រាប់។

យល់ឃើញថា មុននឹងមានវិធានការណ៍បិទទ្វាអាហារដ្ឋាននាយកដ្ឋានបសុព្យាបាល បានជូនដំណឹងអ្នកស្រីលឡរហូតដល់ពេលើកហើយនៅលើកទី៣ អ្នកស្រីបានសុំពន្យាពេលបិទទ្វានៅថ្ងៃទី២៨-៤-៩៧ ដែលបញ្ជាក់ថា អ្នកស្រីបានយល់ ព្រមបិទទ្វារអាហារដ្ឋាននេះហើយ ។

យល់ឃើញថាអ្នកស្រីលឡបានធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ហើយមេធាវីរបស់អ្នកស្រី ក៏ប៉ុនមកចូលរួមសវនាការនេះដែរប៉ុន្តែអ្នកស្រីពុំបានមកចូលរួមសវនាការនេះទេដូច្នេះតុលាការកំពូលជំនុំជំ រះរឿងនេះ កំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលកំបាំងមុខអ្នកស្រី លឡ ប៉ុន្តែចាត់ទុកជាចំពោះមុខ :

១- ទទួលបណ្តឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី១៣-០១-២០០០ របស់លោក គគរ ទុកជាត្រឹមត្រូវ តាមទម្រង់នឹង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១៤ (ក) ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្គាប់ឱ្យអ្នកស្រីលឡម្ចាស់អាហារដ្ឋានសលប្រគល់ទីតាំងឪឡលេខ៤០ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឱ្យទៅនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងឲ្យរុះរើសំណង់ និង សំភារៈចេញពីដីឡូត៍ខាងលើនេះ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោក គគរ បានបង់រួចហើយគឺ ៖

-ពន្ធចុះបញ្ជី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យអ្នកស្រី លឡ សងប្រាក់ចំនួន១៩.០០០៛ ទៅលោកគគរវិញ ។

៥. សាលភានេះជំនុំជំរះ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០០ ។